អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

*ក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសស្រឡាញ់បុរស និងស្រីស្រស់*

# របាយការណ៍សង្ខេបស្ដីពី

# កិច្ចប្រជុំសម្របសម្រួលប្រចាំត្រីមាសគម្រោងស្រីស្រស់

# នៅខេត្តសៀមរាប



ឧបត្ថម្ភថវិកាដោយ:

PEPFAR

USAID

FLAGSHIP

## មាតិកា


១. សារតា............................................................................................................... ១

២. គោលបំណង........................................................................................................ ១

៣. វិធិសាស្ត្រ............................................................................................................ ១

៤. ដំណើរការ និងលទ្ធផលនៃកិច្ចប្រជុំ......................................................................... ២

ក. ការថ្លែងចំណាប់អារម្មណ៍ និងបើកកម្មវិធី................................................................ ២

ខ. ការបង្ហាញពីរបាយការណ៍វឌ្ឍនៈភាពគម្រោងស្រីស្រស់ក្នុងខេត្តសៀមពប....................... ៤

គ. សម្លេងរបស់តំណាងស្រីស្រស់ប្រចាំខេត្តសៀមរាប..................................................... ៦

ឃ. ប្រវត្តិបុរសស្រឡាញ់បុរសឬស្រីស្រស់និងមេរោគអេដស៍នៅកម្ពុជា............................. ៧

ង. អនុសាសន៍ និងសំណូមពរ..................................................................................... ៨

ច. ផែនការបន្ទាប់..................................................................................................... ៨

កម្មវិធីនៃកិច្ចប្រជុំ

# របាយការណ៍សង្ខេបនៃកិច្ចប្រជុំ
# សម្របសម្រួលប្រចាំត្រីមាសគម្រោងស្រីស្រស់

## ១. សាវតា

តាមរយៈគម្រោងផ្លេកស៊ីប ដែលឧបត្ថម្ភថវិកាដោយ USAID អង្គការគ្រួសារសុខភាព អន្តរជាតិ ( FHI360)បានសហការណ៍ជាមួយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍បានរៀបចំកិច្ចប្រជុំប្រចាំត្រីមាសស្តីពីគម្រោងស្រីស្រស់ត្រូវបានរៀបចំឡើងនៅសណ្ឋាគារសោមាទេវីនាថ្ងៃទី ដប់ពីរ ខែ មិថុនា ឆ្នាំ ពីរពាន់ដប់បួន ក្នុងខេត្ត សៀមរាប ដោយមានការចូលរួមពីអាជ្ញាធរជាតិប្រយុទ្ធ នឹងជំងឺអេដស៍ ក្រុមការងារបច្ចេកទេសថ្នាក់ជាតិ បុរសស្រឡាញ់បុរស និងស្រីស្រស់សមាជិកក្រុមប្រឹក្សាខេត្ត ស្នងការខេត្ត ក្រុមប្រឹក្សាស្រុក /ខ័ណ្ឌ-ឃុំ/សង្កាត់ តំណាងគម្រោងផ្លេកស៊ីប អង្គការដែលអនុវត្តកម្មវិធីអេដស៍ និងក្រុមគោលដៅដែលជាក្រុមស្រីស្រស់មកពីសហគមន៍ផ្ទាល់មានប្រមាណជាហុកសិបនាក់ ។

## ២. គោលបំណងកិច្ចប្រជុំ

កិច្ចប្រជុំប្រចាំត្រីមាសនេះ មានគោលបំណងសំខាន់ៗដូចជា:

- ពិនិត្យលើលទ្ធផលការងារនៃគម្រោងស្រីស្រស់ដែលបានអនុវត្តក្នុងរយៈពេលមួយត្រីមាសកន្លងមក
- ពង្រឹងកិច្ចសហការណ៍ និងការចូលរួមរបស់អាជ្ញាធរមូលដ្ឋាន អ្នកផ្តល់សេវាសុខភាព និងអ្នកពាក់ព័ន្ធក្នុងការអនុវត្តគម្រោងស្រីស្រស់ និងមេរោគអេដស៍
- កំណត់យុទ្ធសាស្រ្ត និងយន្តការរួមក្នុងសម្របសម្រួលរវាងអាជ្ញាធរមូលដ្ឋាន និងអ្នកអនុវត្តកម្មវិធីរបស់គម្រោងស្រីស្រស់

## ៣. វិធីសាស្រ្ត

ក្នុងកិច្ចប្រជុំសម្របសម្រួលយ៉ាងមានសារៈសំខាន់នេះ វិធីសាស្រ្តនានា ត្រូវបានប្រើប្រាស់ក្នុង កិច្ចប្រជុំ ដើម្បីធ្វើឱ្យប្រាកដថា កិច្ចពិភាក្សាត្រូវបានចូលរួមយ៉ាងសកម្មពីសមាជិកនីមួយៗ និងដោយមានការយល់ដឹងច្បាស់លាស់លើប្រធានបទដែលត្រូវពិភាក្សា។ យ៉ាងណាមិញ កិច្ចប្រជុំសម្របសម្រួលប្រចាំត្រីមាសសម្រាប់បណ្តាញស្រីស្រស់ ត្រូវបានប្រើប្រាស់វិធីសាស្រ្តសំខាន់ៗមួយចំនួន

ដូចជា ការពិភាក្សាចូលរួម ការពិភាក្សាក្រុមតូច -ធំ បទបង្ហាញ វេទិកាសំណួរ និងចម្លើយ  រវាងអ្នកចូលរួម និងវាគ្មិន និងការផ្តល់ជាអនុសាសន៍ក្នុងការរៀបចំផែនការ ឬសកម្មភាពបន្តបន្ទាប់។

## ៤. ដំណើរការ និងលទ្ធផលនៃកិច្ចប្រជុំ

### ក. ការថ្លែងនូវចំណាប់អារម្មណ៍ និងបើកកម្មវិធី

- *ចំណាប់អារម្មណ៍របស់ប្រធានអង្គការMHC:*លោក ***មៅ គីមរុណា*** នាយកប្រតិបត្តិ នៃអង្គការ MHC បានឡើងថ្លែងនូវចំណាប់អារម្មណ៍ថា កិច្ចប្រជុំសម្របសម្រួលជាមួយអ្នកពាក់ព័ន្ធ ដែលជាពិសេស អាជ្ញាធរមូលដ្ឋាន និងប៉ូលីស ពិតជាមានសារៈសំខាន់ណាស់ ដើម្បីឱ្យលោក  បានយល់ពីស្ថានភាពមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជា ទាក់ទងនឹងក្រុមគោលដៅដែលជាស្រីស្រស់នៅក្នុងខេត្តសៀមរាប។ កិច្ចប្រជុំនេះ មានគោលបំណងសំខាន់ គឺដើម្បីពង្រឹងកិច្ចសហ -ប្រតិបត្តិការ ក្នុងការអនុវត្តការងារ ការផ្តល់សេវាសុខភាព ការកាត់បន្ថយការរើសអើង និងមាក់ងាយ ដល់ក្រុមគោលដៅស្រីស្រស់។ វេទិកានេះ ជាឱកាសផ្តល់ការអប់រំ និងណែនាំដល់ក្រុមគោលដៅឱ្យចេះជួយខ្លួនឯង និងឱ្យចាកឆ្ងាយពីការឆ្លងរីករាលដាលមេរោគអេដស៍។
- *ចំណាប់អារម្មណ៍របស់តំណាង គម្រោង ផ្លេកស៊ីប*លោក ***វេជ្ជ. នី សុជាតិ*** ទីប្រឹក្សាបច្ចេកទេសរបស់អង្គការ ខាណា និងតំណាងឱ្យគម្រោង ផ្លេកស៊ីប បានមានប្រសាសន៍ថា គម្រោងស្រីស្រស់ដែលកំពុងតែបានអនុវត្តដោយអង្គការ  MHC  ជាគម្រោងថ្មី និងជាសកម្មភាពថ្មីផងដែរ ក្នុងការឆ្លើយតប នឹងការរាលដាលមេរោគអេដស៍ក្នុងចំណោមងាយរងគ្រោះ ( MSM, TG, EW, PWUD/PWID)។ ក្នុងចំណោមក្រុមងាយរងគ្រោះទាំងអស់ ក្រុមស្រីស្រស់ជាក្រុមដែលងាយរងផលប៉ះពាល់ជាងគេ ហើយនឹងមានបញ្ហាច្រើនជាងគេដែរ។ ដូចនេះ យើងត្រូវធ្វើការងាររួមគ្នាជាពិសេសការធ្វើការយ៉ាងជិតស្និតជាមួយអាជ្ញាធរមូលដ្ឋាន និងប៉ូលីសមូលដ្ឋាន ដើម្បីឈានទៅសម្រេចគោលដៅនៃគម្រោង និងសម្រេចផែនការសូន្យបីរបស់រដ្ឋាភិបាលក្នុងការប្រយុទ្ធនឹងមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជា។
- *ចំណាប់អារម្មណ៍របស់តំណាងប៉ូលីសមូលដ្ឋាន*លោក ***សារុន សំអូន*** អធិការរងក្រុងសៀមរាប បានប្រសាសន៍ថា ដោយខេត្តសៀមរាប ជាតំបន់ទេសចរណ៍ជាពិសេសមានប្រសាទ  បុរាណជាច្រើន បានធ្វើឱ្យសេដ្ឋកិច្ចប្រជាជននៅតំបន់នេះ កាន់តែមានជីវភាពធូធារ។ ទាក់ទងទៅនឹងក្រុមស្រីស្រស់ នៅក្នុងខេត្ត ក៏មានចំនួនច្រើន ដូចជាមាននៅក្នុងក្លឹប និងកន្លែងកន្សាន្ត  ផ្សេងៗផងដែរ។ ប៉ុន្តែបញ្ហាដែលកើតឡើងជារឿយៗ គឺទាក់ទងទៅនឹងការខូចកេរ្តិ៍ឈ្មោះ និងប៉ះពាល់ដល់តម្លៃរបស់ខ្មែរយើង ដោយសារតែក្រុមស្រីស្រស់មួយចំនួនបានប្រព្រឹត្តនូវបទល្មើស។ ដូចនេះ ខ្ញុំសូមសំណូមពរទៅអង្គការ និងប្អូនៗស្រីស្រស់ផ្ទាល់ដូចទៅ:
    - ត្រូវឈប់ធ្វើទង្វើមិនត្រឹមត្រូវ ឬបទល្មើសផ្សេងៗ
    - បង្កើនការផ្សព្វផ្សាយពីបញ្ហានានារបស់ស្រីស្រស់
    - កុំភ្លើតភ្លើន ឬបង្កបញ្ហាជាមួយភ្ញៀវជាតិ និងអន្តរជាតិ
    - ត្រូវរួមគ្នាជួយអប់រំដល់ក្រុមស្រីស្រស់ទាំងអស់គ្នា

- ***ចំណាប់អារម្មណ៍របស់តំណាងNCHADS:***លោក ***វេជ្ជ. ឡាន វណ្ណសេង***អនុប្រធាន មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើរស្បែក និងកាមរោគ បានលើកឡើងថា ករណីមេរោគអេដស៍ និងជំងឺអេដស៍នេះ នូវតែជាបញ្ហាដ៏ធំមួយសម្រាប់ប្រទេសកម្ពុជាដដែល ហើយក្នុងចំណោមក្រុមងាយរងគ្រោះខ្លាំងបំផុត ដោយសារមេរោគអេដស៍ និងជំងឺអេដស៍គឺមានក្រុមស្រីស្រស់នេះផងដែរ។ ជាងនេះទៅទៀត ក្រុមថ្មីមួយទៀតដែលកំពុងតែប្រឈមមុខខ្លាំងដែរ នោះគឺក្រុមអ្នកប្រើប្រាស់គ្រឿងញៀន ដោយហិត ជក់ ឬចាក់។ ក្រុមអ្នកប្រើប្រាស់គ្រឿងញៀន នៅក្នុងប្រទេសកម្ពុជា មានប្រមាណជា ១៣០០០នាក់ ដែលក្នុងនោះ ១៣០០ នាក់ ជាអ្នកប្រើប្រាស់ដោយចាក់ ហើយអត្រាប្រឈមនឹងឆ្លងមេរោគអេដស៍ មានកម្រិតខ្ពស់បំផុត។ ក្រុមនេះ គឺមានអត្រាប្រើប្រាស់ស្រោមអនាម័យមប្រមាណតែ ៥៩% ប៉ុណ្ណោះ។ ក្នុងការឆ្លើយតបទៅនឹងបញ្ហាដែលកំពុងកើតមានចំពោះក្រុមងាយរងគ្រោះ NCHADS បានបង្កើតនូវយុទ្ធវិធីជំរុញខ្លាំងក្លា ក្នុងការបង្ការ, ថែទាំ និងព្យាបាលបន្តចំពោះក្រុមប្រឈមមុខខ្ពស់នឹងការឆ្លងមេរោគអេដស៍ (Boosted COPCT) ដែលក្នុងនោះ អង្គការ ខាណា ជាដៃគូដ៏សំខាន់ក្នុងការអនុវត្តសកម្មភាព។ កញ្ចប់សេវាសំខាន់ៗរួមមាន:
    - ការផ្តល់ការអប់រំនៅមូលដ្ឋាន
    - ការចែកចាយស្រោមអនាម័យ
    - ការបញ្ជូនទៅទទួលសេវាតេស្តឈាម ដូចជាតេស្តម្រាមដៃ
- ***ចំណាប់អារម្មណ៍ និងបើកកិច្ចប្រជុំរបស់អគ្គលេខាធិការ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជាប្រធានក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសស្រឡាញ់បុរស និងស្រីស្រស់***ឯ.ឧ ***វេជ្ជ. តែង គន្ធី*** មានប្រសាសន៍ថា កិច្ចប្រជុំនេះ គឺដើម្បីដោះស្រាយនូវបញ្ហានានា ដែលកើតមានឡើងចំពោះក្រុមស្រីស្រស់ ដែលផ្តោតសំខាន់លើផ្នែកសុខភាព និងសុខមាលភាពដែល កំពុងតែប្រឈមនៅក្នុងខេត្តសៀមរាប។ ដូចវាលគ្មិនមុនបានលើកឡើងហើយ បញ្ហាការរាលដាលមេរោគអេដស៍ តែងប្រែប្រួលជានិច្ច ដូចនេះហើយត្រូវទាមទារ ឱ្យមានការកំណត់នូវសកម្មភាព និងយុទ្ធសាស្ត្រថ្មីៗនិងជាក់លាក់ ដើម្បីឆ្លើយតបទៅនឹងបញ្ហាឱ្យបានទាន់ពេលវេលា។ ជាងនេះទៀត រដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវគោលនយោបាយថ្មីក្នុងការប្រយុទ្ធប្រឆាំងនឹងការរាលដាលមេរោគអេដស៍នៅកម្ពុជា ដែលមាន ៧ចំណុចសំខាន់ៗ ដូចជា៖
    1. ជំរុញ និង លើកទឹកចិត្ត ឱ្យមានការប្រើប្រាស់ស្រោមអនាម័យ ១០០ %
    2. បញ្ចូលការប្រយុទ្ធនឹងជំងឺអេដស៍ និង សុខភាពមាតា ទៅគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព
    3. រៀបចំផែនទី បញ្ជាក់ពីភូមិសាស្ត្រ ចំនួនអ្នកផ្ទុកមេរោគអេដស៍ ក្រុមងាយរងគ្រោះ
    4. ពង្រឹងលក្ខណៈជាដៃគូ ជាមួយអង្គការសង្គមស៊ីវិលដែលកំពុងដំណើការ នៅក្នុងខេត្តរបស់ខ្លួន ឱ្យមានប្រសិទ្ធភាពខ្ពស់
    5. អនុញ្ញាតឱ្យជនងាយរងគ្រោះដោយជំងឺអេដស៍ ដែលជាអាទិ៍៖ នារីបម្រើសេវាកំសាន្តបុរសស្រឡាញ់បុរស អ្នកញៀនគ្រឿងញៀនប្រើម្ជុល អាចទទួលបានសេវាព្យាបាលជំងឺអេដស៍ បានយ៉ាងទូលំទូលាយ

6. បង្កើនការអប់រំ ដល់យុវជន យុវនារី ឱ្យយល់ដឹងពីគ្រោះថ្នាក់នៃជំងឺអេដស៍ និង វិធីបង្ការ ការពារ ឱ្យបានទូលំទូលាយ
7. អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ មានតួនាទីដឹកនាំ សម្របសម្រួល និង តាមដានការអនុវត្តការងារឆ្លើយតបនឹងមេរោគអេដស៍



*គណៈអធិបតីនៃកិច្ចប្រជុំ*

## ខ. ការបង្ហាញពីរបាយការណ៍វឌ្ឍនៈភាពគម្រោងស្រីស្រស់ក្នុងខេត្តសៀមរាប

(អ្នកសម្របសម្រួល: លោក ទ្រី ប៊ុនហាក់ មន្ត្រីសម្របសម្រួលប្រចាំខេត្ត របស់អង្គការ MHC)

អ្នកសម្របសម្រួល បានបង្ហាញពីការអនុវត្តការងាររបស់អង្គការ MHC ដែលសម្រេចបានក្នុងត្រីមាសទី៣ នេះ ដូចខាងក្រោម៖



*លទ្ធផលសម្រេចបានក្នុងក្លឹបស្រីស្រស់គិតចាប់ពីខែមីនាមកដល់ខែមិថុនាឆ្នាំ២០១៤*

| ល.រ | លទ្ធផលដែលសម្រេចបាន | ចំនួន |
|---|---|---|
| ១ | កម្មវិធីព្រឹត្តិការណ៍ពិសេស | ០៣ ដង២៥០នាក់ |
| ២ | ចំនួនស្រីស្រស់ចូលជាសមាជិក | ១៦១នាក់ |
| ៣ | ស្រីស្រស់បានទទួលការអប់រំនៅក្លឹប | ៤២២នាក់ |

*ចំនួនក្រុមគោលដៅដែលបានទទួលសេវាធ្វើតេស្តឈាមរកមេរោគអេសដ៍និងស្វាយៈ*




*បញ្ហាប្រឈមៈ*

- ស្រីស្រស់រវល់ទៅតែងការនៅតំបន់ឆ្ងាយៗពិបាកក្នុងការណាត់ជួបអប់រំនិងធ្វើតេស្តឈាម
- សមត្ថកិច្ចមានផែនការបោសសំអាតនិងចាប់ដោយគ្មានមូលហេតុច្បាស់លាស់ មកលើក្រុមស្រីស្រស់នៅតាមកន្លែងប្រមូលផ្តុំមួយចំនួនដែលនាំឲ្យពិបាកជួបជុំនិងប្រមូលធ្វើតេស្តឈាម
- ស្រីស្រស់មួយចំនួនផ្លាស់ប្តូរទីកន្លែងញឹកញាប់ដែលពិបាកស្វែងរក
- អ្នកជំងឺកាមរោគដែលជាក្រុមស្រីស្រស់ទៅព្យាបាលដោយបង់ប្រាក់ថ្លៃពិនិត្យនិងទិញថ្នាំព្យាបាលជំងឺ

- ខ្វះខាតគ្រូពេទ្យជំនាញសំរាប់ពិនិត្យក្រុមស្រីស្រស់នៅគ្លីនិកកាមរោគ

*សំណូមពរ និងអនុសាសន៍:*

- សូមឲ្យមានគ្រូពេទ្យជំនាញសំរាប់ពិនិត្យក្រុមស្រីស្រស់នៅគ្លីនិកកាមរោគ
- សូមឲ្យមានក្រមសីលធម៌វិជ្ជាជីវៈក្នុងនាមជាគ្រូពេទ្យឬក្នុងនាមជាអ្នកផ្តល់សេវាសុខភាព
- សូមសំណូមពរឲ្យខាងសមត្ថកិច្ចចាប់ឬឃាត់ខ្លួនតែស្រីស្រស់ណាដែលបានប្រព្រឹត្តខុសនិងច្បាប់រដ្ឋតែប៉ុណ្ណោះនិងសូមកុំឲ្យមានការធ្វើទារុណកម្មមកលើស្រីស្រស់
- សំណូមពរឲ្យមានក្រុមមេធាវីឬតំណាងអ្នកច្បាប់សំរាប់ជួយអន្តរាគមន៍នៅពេលដែលមានការចាប់ក្រុមស្រីស្រស់ដោយមិនមានហេតុផលត្រឹមត្រូវនិងច្បាស់លាស់
- សំណូមពរឲ្យអាជ្ញាធរអេដស៍មេត្តាជួយជម្រុញការផ្សព្វផ្សាយនិងធ្វើការសម្របសម្រួលជាមួយបណ្តាអង្គភាពផ្សេងៗ ស្ថាប័ន ពាក់ព័ន្ធទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិឲ្យបានដឹងច្បាស់ពីទស្សនៈ និងគោលការណ៍របស់អង្គការដែលធ្វើការងារទៅលើកម្មវិធីអេដស៍ក្នុងការចូលរួមទប់ស្កាត់ការីករាលដាលថ្មីនៃមេរោគអេដស៍នៅកម្ពុជា
- បង្កើនវគ្គបណ្តុះបណ្តាលដល់ក្រុមការងាររបស់អង្គការជាដៃគូរដែលពាក់ព័ន្ធនិងកម្មវិធីអេដស៍ឲ្យបានដឹងច្បាស់និងចំណេះដឹងបន្ថែមទៀតដើម្បីងាយស្រួលដល់ក្រុមការងារចុះអនុវត្តកម្មវិធីតាមសហគមន៍ជាមួយក្រុមគោលដៅ

## គ. សម្លេងរបស់តំណាងស្រីស្រស់ប្រចាំខេត្តសៀមរាប

តំណាងក្រុមស្រីស្រស់ ***កញ្ញាឃឹម ស៊ីវ៉ាត់*** បានឡើងបង្ហាញពីជីវិតពិតរបស់ខ្លួន និងបទពិសោធនៃការរើសអើង និងមាក់ងាយពីសំណាក់អាជ្ញាធរមានសមត្ថភាព។ មូលហេតុចំបងដែលនាងក្លាយជាស្រីស្រស់ក៏ដោយសារតែធម្មជាតិ និងចំណង់ចំណូលចិត្តរបស់នាងតាំងពីកំណើត។ នាងត្រូវបានឪពុកម្តាយ និងបងប្អូនមិនអនុញ្ញាតិឱ្យធ្វើខ្លួនជាស្រីទេ ដោយខុសពីមនុស្សទូទៅព្រោះខ្លួនជាមនុស្សប្រុស។ នាងត្រូវបានរងការរិះគុណពីអ្នកជិតខាងនិងបងប្អូនព្រោះតែងខ្លួននិងធ្វើ ចរិតឬកពារជាមនុស្សស្រី។

បន្ថែមពីនេះទៀត ក្នុងពេលថ្មីៗនេះ នាងរងនូវការធ្វើបាប និងចាប់ដាក់ឃុំខ្លួនដោយ មិនដឹងមូលហេតុ។ ស៊ីវ៉ាត់លើកឡើងថា *"នៅពេលដែលខ្ញុំកំពុងឈរ ម៉ុំផ្សារពេត្រីក្រុមប៉ូលីសមកចាប់ខ្ញុំដោយមិនដឹងមូលហេតុ ទោះបីជាខ្ញុំ ខិតខំបកស្រាយប្រាប់គាត់ (ប៉ូលីស) យ៉ាងណាក៏គាត់មិនព្រមដែរ*។

ជាចុងក្រោយនាងសំណូមពរទៅកាន់អ្នកចូលរួមទាំងអស់ ជាពិសេសអាជ្ញាធរមូលដ្ឋាន និងប៉ូលីសកុំឱ្យមានការរើសអើងចំពោះអ្នកស្រឡាញ់ភេទដូចគ្នា ហើយមុននឹងចាប់ខ្លួនក្រុមស្រី

ស្រស់ត្រូវមានភស្តុតាងឱ្យបានច្បាស់លាស់កុំចេះតែ ដើរចាប់ខ្លួនមិនរើសមុខឱ្យតែស្រីស្រស់នោះ។



*អ្នកចូលរួមមកពីស្ថាប័នរដ្ឋាភិបាល*

## ឃ. ការបង្ហាញពីប្រវត្តិនៃក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់ និងការរីករាលដាលមេរោគអេដស៍នៅកម្ពុជា

(អ្នកសម្របសម្រួល: ***ឯ.ឧ តែង គន្ធី***អគ្គលេខាធិការ នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍)

**ឯ.ឧ តែង គន្ធី** បានធ្វើការគូសបញ្ជាក់ថា បុសស្រឡាញ់បុរស ឬស្រីស្រស់ សំដៅទៅលើបុរសរួមភេទជាមួយបុរស និងបុរសដែលរួមភេទជាមួយបុរសផង និងរួមភេទជាមួយស្ត្រីផង។

បុរសរួមភេទជាមួយបុរស ឬស្រីស្រស់មានប្រវត្តិជាយូរយារណាស់មកហើយ ដែលគេបានរកឃើញនៅលើផ្ទាំងថ្មនៃប្រទេសបារាំង រកឃើញក្នុងផ្នូរបុរាណនៃប្រទេសអេស៊ីប ផ្ទាំងគំនូរបុរាណរបស់អ៊ីតាលី និងសម័យបុរាណនៃប្រទេសចិន។ យ៉ាងណាមិញ នៅប្រទេសកម្ពុជា ត្រូវបានគេរកឃើញក្នុងសម័យចេនឡាតាមរយៈកំណត់ត្រារបស់ជីវតាក្វាន់។
ជារួមអ្នកស្រឡាញ់ភេទដូចគ្នា គឺកើតមានឡើងតាំងពីកំណើត ឬដោយធម្មជាតិ។

**ឯ.ឧ តែង គន្ធី** ក៏បានធ្វើការបញ្ជាក់ថាលើស្ថានភាពមេរោគអេដស៍ និងជំងឺអេដស៍ក្នុងចំណោមក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់នៅកម្ពុជាថា:

- តាមការសិក្សានៅឆ្នាំ២០០៥មាន៨.៧% នៅភ្នំពេញនិង០.៨% នៅខេត្ត។
- តាមការអង្កេតនៅឆ្នាំ២០០៧អត្រាអេដស៍មានកំរិតខ្ពស់ក្នុងចំណោមក្រុមTG មាន៩.៨% បើប្រៀបធៀបទៅនឹងMSM មានតែ៥.១%។
- តាមការសិក្សារបស់ប្រុសខ្មែរ (FHI360) ឆ្នាំ២០១០មាន២.១%។

ការឆ្លើយតបថ្នាក់ជាតិទូលំទូលាយមានដូចជា:

- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ដែលជាស្ថាប័នជំនាញខាងមេរោគអេដស៍ និងជំងឺអេដស៍ (ផែនការយុទ្ធសាស្ត្រជាតិ)
- ក្រុមការងារថ្នាក់ជាតិបុរសស្រឡាញ់បុរស និងស្រីស្រស់
- បណ្តាញថ្នាក់ជាតិបុរសស្រឡាញ់បុរស និងអង្គការសហគមន៍ធ្វើការជាមួយក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់
- គោលគំនិតផ្តួចផ្តើមថ្មីៈ
  - ✓ យុទ្ធវិធីជំរុញខ្លាំងក្លាការបង្ការ, ថែទាំ និងព្យាបាលបន្តចំពោះក្រុមប្រឈមមុខ ខ្ពស់នឹងការឆ្លងមេរោគអេដស៍(Boosted COPCT);
  - ✓ យុទ្ធវិធីជំរុញខ្លាំងក្លានូវការអនុវត្តការថែទាំ និងព្យាបាលបន្ត (Boosted CoC)

## ង. អនុសាសន៍ និងសំណូមពរ

តាមរយៈការពិភាក្សាគ្នារួចមក សមាជិកស្នើឱ្យ MHC ពិនិត្យលើអនុសាសន៍ដូចខាងក្រោម:

- អង្គការ MHC ត្រូវធ្វើផែនការរួមគ្នាជាមួយអាជ្ញាធរមូលដ្ឋាន និងប៉ូលីស
- ត្រូវអនុវត្តការងារដោយទទួលខុសត្រូវខ្ពស់ និងមានប្រសិទ្ធភាពព្រមទាំងបទបែនទៅតាមកាលៈទេសៈរបស់ក្រុមគោលដៅ
- ត្រូវធ្វើការសហការណ៍ និងបង្ហាញផលប៉ះពាល់ដល់ប៉ូលីសក្នុងករណីក្រុមស្រីស្រស់បានប្រព្រឹត្តបទល្មើស ហើយស្ថិតក្នុងស្ថានភាពផ្ទុកមេរោគអេដស៍
- អង្គការ MHC ត្រូវធ្វើការទំនាក់ទំនងយ៉ាងជាប់លាប់ជាមួយអាជ្ញាធរមូលដ្ឋាន ដោយបំពេញនូវឯកសារចាំបាច់ផ្សេងៗ ព្រមទាំងធ្វើរបាយការណ៍ឱ្យបានទៀងទាត់ផ្ញើទៅ NAA និងអាជ្ញា-ធរមូលដ្ឋាន

## ច. ផែនការបន្ទាប់

- អង្គការ MHC ត្រូវរៀបចំកិច្ចប្រជុំជាមួយប៉ូលីសមូលដ្ឋាន ដោយដាកបញ្ចូលនូវប្រធាន បទសំខាន់ៗដូចជា ក្រមសីលធមិសម្រាប់ស្រីស្រស់ និងមន្ត្រីប៉ូលីស ផលវិបាកការទទួលថ្នាំ ART ទៀងទាត់ និងការចូលរួមចំណែករបស់ប៉ូលីសក្នុងការទប់ស្កាត់ ការរាលរាលមេរោគអេដស៍
- អង្គការ MHCត្រូវបង្កើនកិច្ចសហការណ៍ជាមួយអាជ្ញាធរមូលដ្ឋាន តាមរយៈការផ្តល់នូវ ទិន្ន-ន័យជាក់លាក់ពីគម្រោង ចំនួនស្រីស្រស់ ដាក់បញ្ចូលផែនការរួមគ្នា និងកំណត់យន្តការសម្របសម្រួលរួមគ្នា។

## កម្មវិធីកិច្ចប្រជុំ

| ម៉ោង | សកម្មភាព | អ្នកទទួលសុខត្រូវ |
|---|---|---|
| 7:30-8:00 am | ការចុះឈ្មោះអ្នកចូលរួម | លោក ហេង សាលី |
| 8:00- 8:05 am | គោរពភ្លេងជាតិ | ពិធីករ |
| 8:05- 8:10 am | ចំណាប់អារម្មណ៍ប្រធានអង្គការ MHC | លោក ម៉ៅ គឹមរុន |
| 8:10- 8:20 am | ចំណាប់អារម្មណ៍របស់តំណាងសម្ព័ន្ធ Flagship | លោក ផល សុផាត |
| 8:20-8:30 am | ចំណាប់អារម្មណ៍របស់ ប្រធាន ការិយាល័យអេដស៍ខេត្ត | លោកសារ៉ាត់ |
| 8:30-8:40 am | ចំណាប់អារម្មណ៍របស់តំណាង NCHADS | វេជ្ជ. ឡាន វណ្ណសេង អនុប្រធាន NCHADS |
| 9:40-9:00 am | មតិស្វាគមន៍ និងបើកកម្មវិធីដោយឯកឧត្តមអគ្គលេខាធិការ នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងប្រធានក្រុមការងារ បច្ចេកទេសថ្នាក់ជាតិបុរសស្រលាញ់បុរសនឹងក្រុមស្រីស្រស់ | ឯ.ឧ វេជ្ជ. តែង គន្ធី |
| 9:00-9:30 am | ការបង្ហាញដោយសង្ខេបពីរបាយការណ៍វឌ្ឍនៈភាពក្នុងការអនុវត្តគម្រោងស្រីស្រស់ក្នុងខេត្តសៀមរាប | លោក កែម វិចិត្រ ប្រធានកម្មវិធីរបស់អង្គការ MHC |
| 9:30-9:45 am | អាហារសម្រន់ | សណ្ឋាគារ |
| 9:45-10:00am | សម្លេងរបស់ស្រីស្រស់ | តំណាង TG |
| 10:00-11:30am | បទអន្តរាគមន៍ និងពិភាក្សាពេញអង្គ បញ្ហាប្រឈមនិងដំណោះស្រាយ ការចូលរួមពីស្ថាបន័ពាក់ពន្ធ័អាជ្ញាធរមូលដ្ឋាន ប៉ូលីស និងសេវាសុខភាព កាត់បន្ថយការរើសអើងជាមួយប្រព័ន្ធពត៌មាន | ឯ.ឧ តែង គន្ធី |
| 11:30-11:50 am | មតិចូលរួមរបស់តំណាងស្ថាប័នពាក់ព័ន្ធ | តំណាងចូលរួម |
| 11:50-12:00 am | មតិបូកសរុប និងបិទកម្មវិធី | ឯ.ឧ តែង គន្ធី |
| 12:00 - | អាហារសាមគ្គីរួមគ្នា | សណ្ឋាគារ |